www.SmaradeyKhmer.org
Email: nphalla@hotmail.com

# បុណ្យជាមិត្រ

ស្រង់ពី មិត្រកថា របស់លោកគ្រូអាចារ្យ យូ – អ៊ុន

មនុស្សយើងត្រូវអាស្រ័យដោយគុណធម៌ គឺការមានមេត្រីចិត្ត ។ សេចក្តីស្រឡាញ់ និង បំណងល្អ ចំពោះគ្នានេះជាបច្ច័យទាក់ទាញចិត្តរបស់បុគ្គលឲ្យបង្អោនចូលរកគ្នាទៅវិញទៅមកហើយសម្រេចនូវផលល្អ ដូចជាសេចក្តីទំនុកបម្រុងសង្គ្រោះគ្នាបានពេញទីជាដើម ។ មនុស្សក្នុងភពមណ្ឌលដែលមានការជាប់ទាក់ទងគ្នាត្រូវតែជាមិត្រនឹងគ្នាផងទើបប្រព្រឹត្តទៅដោយសុខសួស្តីបាន ។

ពុទ្ធភាសិតមួយបានពោលថា:

"ពួកឈ្មួញជាមិត្ររបស់អ្នកដើរផ្លូវឆ្ងាយ
មាតាបិតាជាមិត្រក្នុងផ្ទះរបស់ខ្លួន
សម្លាញ់ជាមិត្ររបស់មនុស្សអ្នកមានកិច្ចធុរៈរឿយៗ
បុណ្យទាំងឡាយដែលគេធ្វើទុកដោយខ្លួនឯងជាមិត្រជិតជាប់តាមទៅក្នុងភពខាងមុខ"

"សម្លាញ់" និង "មិត្រ" មានន័យផ្សេងគ្នា ។ **សម្លាញ់** សំគាល់យកជនដែលជាក្លើ ឬ គូកនមានការងារឬដំណើរត្រូវគ្នានឹងខ្លួន ។ **មិត្រ** គឺជនដែលរួមសុខរួមទុក្ខ, ជួយបំបាត់ជួយការពារមិនឲ្យមានអន្តរាយ, មានសេចក្តីស្រឡាញ់រាប់រកគ្នាដោយទឹកចិត្តសុចរិត, ស្និទ្ធស្នាលគួរទុកចិត្តគ្នាបាន ។

**កល្យាណមិត្រ** គឺមិត្រដែលបណ្ឌិតគួររាប់រក តែងពន្យល់បុគ្គលដែលចូលមកសេពគប់ឲ្យប្រកបកិច្ចដែលគួរប្រកប ដឹកនាំឲ្យធ្វើអំពើកុសល ដឹកនាំឲ្យរៀនសូត្រវិជ្ជាសិល្បសាស្ត្រក្នុងផ្លូវលោកផ្លូវធម៌ ដើម្បីឲ្យពួកជនដែលចូលមកសមាគមមានសេចក្តីចំរើនដោយសេរីសួស្តី ។ កល្យាណមិត្រ គឺគ្រូបង្រៀនណែនាំពន្យល់បង្ហាត់បង្ហាញនូវចំណេះនឹងវិជ្ជាសិល្បសាស្ត្រផ្សេងៗនិងគុណវិសេសផង ។ ផ្ទុយពីបាបមិត្រដែលនាំឲ្យវិនាស កល្យាណមិត្រតែងនាំឲ្យមានសេចក្តីចំរើន ។

លក្ខណៈនៃកល្យាណមិត្រមាន ៣ ប្រការ គឺ :

១. ហាមឃាត់គ្នាក្នុងការឥតប្រយោជន៍
២. ដឹកនាំគ្នាក្នុងការដែលមានប្រយោជន៍
៣. មិនលះបង់គ្នាក្នុងគ្រាដែលមានសេចក្តីវិនាស
ទាំងនេះមានក្នុងមិត្រ ២ ពួក គឺមិត្រជាគ្រហស្ថ និង មិត្រជាបព្វជិត ។

សង្កេតមិត្រជាបព្វជិតដោយអង្គ ៧ ប្រការគឺ :

១. ធ្វើខ្លួនឲ្យគេស្រឡាញ់
២. ធ្វើខ្លួនឲ្យគេគោរព
៣. អប់រំបន្ទុំខ្លួនឲ្យចំរើនល្អមជាទីសរសើរ
៤. ឧស្សាហ៍ប្រៀនប្រដៅ
៥. អត់ធន់ចំពោះពាក្យ
៦. រំគាយអធិប្បាយសេចក្តីឲ្យជ្រៅដោយលំដាប់
៧. មិនដឹកនាំក្នុងរបស់ដែលមិនគួរសិក្សារ

សង្កេតមិត្រជាគ្រហស្ថដោយអង្គ ៧ ប្រការគឺ :

១. ឲ្យរបស់ដែលគេឲ្យបានដោយកម្រ
២. ធ្វើរបស់ដែលគេធ្វើបានដោយកម្រ
៣. អត់ធន់ចំពោះហេតុដែលគេអត់ធន់បានដោយកម្រ
៤. ប្រាប់សេចក្តីកំបាំងរបស់ខ្លួនដល់សម្លាញ់
៥. ជួយបិតបាំងសេចក្តីកំបាំងរបស់សម្លាញ់មិនផ្សាយចេញ
៦. មិនលះបង់គ្នាក្នុងវេលាមានអន្តរាយ
៧. មិនមើលងាយព្រោះសម្លាញ់មានសេចក្តីក្រើក្រ

ឈ្មួញ មាតាបិតា និង សម្លាញ់ នាំឲ្យកើតផលល្អជួយគ្នាឲ្យបាននូវសេចក្តីសុខបានត្រឹមតែក្នុងបច្ចុប្បន្នប៉ុណ្ណោះ រីឯអនាគត ឬ ភពខាងមុខវិញ ត្រូវពឹងលើមិត្រដ៏វិសេសវិសាលមួយទៀតគឺបុណ្យកុសលដែលសាធុជនបានសាងសន្សំទុកក្នុងសន្តាន ។

**បុណ្យ ប្រែថា "កុសលជាគ្រឿងលាងជំរះចិត្ត" រឺ "អំពើល្អ"**
បាប ប្រែថា "អកុសលជាគ្រឿងសៅហ្មង" រឺ "អំពើអាក្រក់"

បុណ្យ បានដល់ធម្មជាតិដែលនុសជំរះសន្តានចិត្តរបស់សត្វឲ្យជ្រះថ្លាបិរសុទ្ធ, ជាកល្យាណមិត្ររបស់អ្នកដែលប្រព្រឹត្តសុចរិតដោយកាយ វាចា ចិត្ត, នាំសត្វឲ្យទៅកើតក្នុងសុគតិ គឺ មនុស្ស សួគ៌ ទេវលោក, នាំសេចក្តីសុខមកប្រគល់ឲ្យសត្វដែលប្រព្រឹត្តល្អ ។

បុណ្យនេះចែកចេញជា ២ ប្រការ គឺ បុណ្យជាហេតុ ១ បុណ្យជាផល ១ ។ បុណ្យជាហេតុនោះបានដល់កុសលធម៌ដែលលាងជម្រះដួងចិត្តឲ្យបរិសុទ្ធស្អាតផូរផង់ប្រាសចាកសង្កិលេសធម៌ទាំងពួង មានលោភៈ ទោសៈ មោហៈ ជាដើម ព្រោះថាកុសលធម៌នេះបើកើតឡើងក្នុងសន្តាននៃបុគ្គលណា រមែងធ្វើចិត្តរបស់បុគ្គលនោះឲ្យបរិសុទ្ធឃ្លាតចាកសេចក្តីអាក្រក់ នឹងធ្វើអំពើអ្វី និយាយការអ្វី គិតហេតុអ្វីសុទ្ធតែជាសុចរិត មានកាយ វាចា ចិត្ត បរិសុទ្ធគ្រប់ត្រៃទ្វារ ។ ឯបុណ្យជាផលនោះបានដល់សេចក្តីសុខដែលកើតឡើងដល់អ្នកបំពេញ មានឲ្យកើតសេចក្តីរីករាយពេញចិត្តជាដើម ។

## បុញ្ញកិរិយាវត្ថុ រឺ ការសន្សំនូវបុណ្យកុសលមាន ១០ ប្រការគឺ :

១. **ទាន** ការបរិច្ចាគទ្រព្យរបស់ដោយសេចក្តីអនុគ្រោះក៏មាន ដោយបូជាគុណក៏មាន ដោយការទំនុកបម្រុងក៏មាន ដើម្បីឲ្យអ្នកទទួលបានសម្រេចប្រយោជន៍, ទាននេះជាគ្រឿងកំចាត់បង់លោភៈ ។
២. **សីល** ការរក្សាកាយវាចា ឲ្យរៀបរយជាប្រក្រតី, សីលនេះជាគ្រឿងកំចាត់បង់ ទោសៈ ។
៣. **ភាវនា** ការធ្វើចិត្តឲ្យស្ងប់និងអប់រំប្រាជ្ញាឲ្យមុះមុត ឲ្យឃើញច្បាស់តាមពិត, ភាវនានេះជាគឿងកំចាត់បង់ មោហៈ ។

៤. **អបចាយន** ការសំដែងសេចក្ដីលំអុតលំឱនគោរពកោតខ្លាចចំពោះបុគ្គលដែលចំរើនដោយវ័យ ឬ ដោយគុណមានសីលគុណជាដើម, អបចាយននេះជាគ្រឿងកំចាត់ការប្រកាន់ខ្លួន និង ការមើលងាយអ្នកដ៏ទៃ ។

៥. **វេយ្យាវច្ច** ការខ្វល់ខ្វាយខ្នះខ្នែងធ្វើកិច្ចធុរៈរបស់អ្នកដទៃដែលគួរជួយគួរធ្វើ, វេយ្យាវច្ចនេះ ជាគ្រឿងកំចាត់បង់ កោសជ្ជ (សេចក្ដីខ្ជិលច្រអូស) ។

៦. **បត្តិទាន** ការឧទ្ទិសចំណែកបុណ្យ គឺធ្វើបុណ្យណាមួយហើយជូនផលបុណ្យនោះដល់អ្នកដទៃ, បត្តិទាននេះជាគ្រឿងកំចាត់បង់ អរតិ (សេចក្ដីមិនត្រេកអរ) និង វណ្ណមច្ឆរិយៈ (សេចក្ដីកំណាញ់គុណរបស់អ្នកដទៃ) ។

៧. **បត្តានុមោទនា** ការទទួលត្រេកអរចំពោះចំណែកបុណ្យដែលអ្នកដទៃឧទ្ទិសឲ្យ, បត្តានុមោទនានេះ ជាគ្រឿងកំចាត់បង់ ឥស្សា (ការច្រណែនសេចក្ដីល្អរបស់អ្នកដទៃ ) ។

៨. **ធម្មស្សវន** ការស្ដាប់ធម៌ ឬ ទទួលស្ដាប់ឱវាទរបស់អ្នកប្រាជ្ញដោយគោរព, ធម្មស្សវននេះជាគ្រឿងកំចាត់នូវការមិនដឹងច្បាស់ និង ថម្ភៈមានៈអតិមានៈ ។

៩. **ធម្មទេសនា** ការសំដែងធម៌នាំអ្នកដទៃទាំងគតិលោក គតិធម៌, ធម្មទេសនានេះជាគ្រឿងកំចាត់ នូវការមិនដឹងច្បាស់របស់អ្នកដទៃ និង កំចាត់បង់នូវធម្មមច្ឆរិយៈ (សេចក្ដីកំណាញ់ធម៌) ។

១០. **ទិដ្ឋុជុកម្ម** ការធ្វើទិដ្ឋិឲ្យត្រង់ គឺធ្វើសេចក្ដីយល់ឃើញឲ្យត្រង់តាមគន្លងធម៌, ទុដ្ឋុជុកម្មនេះ ជាគ្រឿងកំចាត់សេចក្ដីឃើញខុស, (ការធ្វើសេចក្ដីយល់ឃើញខុសឲ្យត្រង់បាននេះជាគុណយ៉ាងសំខាន់បំផុតក្នុងផ្លូវប្រតិបត្តិធម៌, ព្រោះថាបើបុគ្គលមានសេចក្ដីឃើញខុសហើយ ការប្រព្រឹត្តផ្លូវកាយ វាចា ចិត្ត ក៏អាចខុសទៅតាម, បើមានសេចក្ដីយល់ឃើញត្រង់ត្រូវតាមផ្លូវធម៌ហើយ ការប្រព្រឹត្តិផ្លូវកាយវាចាចិត្តក៏ត្រង់ត្រូវទៅតាម) ។

- បុណ្យឲ្យផលដល់អ្នកបំពេញ :
  សាធុជនទាំងឡាយដែលបានបំពេញបុណ្យកុសលទុកក្នុងសន្ដានហើយ, កាលបើបានពិនិត្យមើលនូវ ការប្រព្រឹត្តផ្លូវកាយ វាចា និង ចិត្ត របស់ខ្លួនដែលបានធ្វើឃើញសុទ្ធតែជាបុណ្យកុសលទាំងអស់, ក៏រមែងកើតបីតិសោមនស្សរីករាយក្នុងចិត្ត ។
- បុណ្យជាមន្តអាគមស្នេហ៍មុខ :
  បុគ្គលនោះរមែងជាទីស្រឡាញ់ពេញចិត្តនៃមនុស្សនិងទេពតាទាំងឡាយកាលបើបានសន្សំធ្វើបុណ្យ ទុកក្នុងសន្ដានជាស្រេច ។